**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានពិសេស
# និងកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេស ស្តីពីជំងឺឆ្លងផ្លូវដង្ហើមកូវីដ-១៩
# តាមរយៈប្រព័ន្ធវីដេអូ ( Video Conference )
# នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ រាជធានីភ្នំពេញ

*****

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាន អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានពិសេស និងកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេស ស្តីជំងឺឆ្លងផ្លូវដង្ហើមកូវីដ-១៩ ( COVID-19 ) តាមរយៈប្រព័ន្ធវីដេអូ ( Video Conference ) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០។ ប្រទេសវៀតណាម ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២០ ជាប្រធានកិច្ចប្រជុំទាំងពីរនេះ ហើយទទួលបាននូវលទ្ធផលដូចតទៅ៖

<u>កិច្ចប្រជុំកំពូលអាស៊ានពិសេស ស្តីជំងឺកូវីដ-១៩ ( COVID-19 )</u>

ប្រមុខរដ្ឋ/រាជរដ្ឋាភិបាលអាស៊ានបានជួបគ្នាជាលើកដំបូង តាមរយៈប្រព័ន្ធវីដេអូ ដោយមានការសម្របសម្រួលពីវៀតណាម ដែលជាប្រធានអាស៊ានឆ្នាំ២០២០ ដើម្បីពិភាក្សាអំពីវិធានការដែលអាស៊ានអាចធ្វើការរួមគ្នា ក្នុងការដោះស្រាយជំងឺរាតត្បាតកូវីដ-១៩ និងផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ចក្នុងតំបន់។

ថ្នាក់ដឹកនាំអាស៊ាន បានបញ្ជាក់ពីតម្រូវការដើម្បីពង្រឹងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការតំបន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងស្មារតីនៃសហគមន៍អាស៊ានដែលមានភាពស្អិតរមួត និងភាពឆ្លើយតប តាមរយៈការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងឧត្តមានុវត្តន៍នៃវិធីសាស្ត្រព្យាបាលវេជ្ជសាស្ត្រ ព្រមទាំងការលើកកម្ពស់ការសម្របសម្រួលគោលនយោបាយ ដើម្បីកាត់បន្ថយផលប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ច និងសង្គមដែលបណ្តាលមកពីជំងឺរាតត្បាតនេះ ការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋអាស៊ាន ក៏ដូចជារក្សាឱ្យបាននូវស្ថិរភាពផ្នែកសង្គម-សេដ្ឋកិច្ច។

ថ្នាក់ដឹកនាំអាស៊ានបានបង្ហាញការប្តេជ្ញាចិត្តក្នុងការរក្សាទីផ្សារអាស៊ានឱ្យបើកចំហសម្រាប់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគក្នុងគោលបំណងពង្រឹងភាពរឹងមាំ និងនិរន្តរភាពនៃសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ជាពិសេសលើការផ្គត់ផ្គង់ស្បៀងអាហារ សម្ភារៈវេជ្ជសាស្ត្រ និងផលិតផលចាំបាច់នានា។ ក្នុងបរិការណ៍នេះ ថ្នាក់ដឹកនាំអាស៊ានក៏បានចាត់ឱ្យរដ្ឋមន្ត្រី និងឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន ស្វះស្វែងរកវិធានការចាំបាច់



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

នានា ដើម្បីរក្សាការតភ្ជាប់សង្វាក់ផ្គត់ផ្គង់ ការធានានូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់ការធ្វើពាណិជ្ជកម្ម និងទប់ស្កាត់ការដាក់កំហិតដែលមិនចាំបាច់នានា លើលំហូរស្បៀងអាហារ សម្ភារៈវេជ្ជសាស្ត្រ និង ផលិតផលចាំបាច់នានា។

ថ្នាក់ដឹកនាំអាស៊ាន បានគាំទ្រចំពោះការរៀបចំឡើងវិញនូវប្រាក់មូលនិធិនានាដែលមានស្រាប់ និង លើកទឹកចិត្តដល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីដៃគូអាស៊ាន ដើម្បីសម្របសម្រួល កិច្ចសហប្រតិបត្តិការប្រឆាំងជំងឺកូវីដ-១៩ ដោយរួមទាំងសំណើបង្កើតមូលនិធិឆ្លើយតបបន្ទាន់សម្រាប់ជំងឺ កូវីដ-១៩ ដើម្បីដោះស្រាយនូវកង្វះខាតសម្ភារៈវេជ្ជសាស្ត្រ ការគាំទ្រលើការស្រាវជ្រាវ និងការអភិវឌ្ឍនៃ ឱសថនិងវ៉ាក់សាំង ព្រមទាំងការត្រៀមរៀបចំឆ្លើយតបបន្ទាន់នាពេលអនាគត។ ឈរលើស្មារតីនេះ ថ្នាក់ដឹកនាំអាស៊ាន បានស្នើក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ត្រួតពិនិត្យមើលលើកិច្ចប្រឹងប្រែង សម្របសម្រួលនានារបស់អាស៊ានដែលឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងដោះស្រាយបញ្ហាប្រឈម ទៅលើស្ថានភាពសង្គម-សេដ្ឋកិច្ច និងរាយការណ៍ជាទៀងទាត់ជូនថ្នាក់ដឹកនាំអាស៊ាន អមជាមួយនឹង អនុសាសន៍សមស្របផ្សេងៗ សម្រាប់ការណែនាំបន្ថែមទៀត។

ថ្នាក់ដឹកនាំបានសង្កត់ធ្ងន់អំពីសារៈសំខាន់សម្រាប់អាស៊ានក្នុងការចូលរួមយ៉ាងជិតស្និទ្ធជាមួយដៃគូ ខាងក្រៅ រួមមានដៃគូសន្ទនាអាស៊ាន អង្គការសុខភាពពិភពលោក និងសហគមន៍អន្តរជាតិនានា ចំពោះ កិច្ចខិតខំប្រឹងប្រែងក្នុងការការពារ បញ្ឈប់ និងគ្រប់គ្រងការឆ្លងជំងឺនេះ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំ អាស៊ានបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការពង្រឹង និងការបន្តប្រើប្រាស់យន្តការថ្នាក់តំបន់ និងអន្តរជាតិ ដែលមានស្រាប់ ដើម្បីសហការ និងសម្របសម្រួលក្នុងការឆ្លើយតបចំពោះវិបត្តិសុខភាពសាធារណៈនេះ។

ក្នុងឱកាសកិច្ចប្រជុំនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានគូសបញ្ជាក់អំពីអាទិភាព មួយចំនួន ដូចជា៖(១)គាំទ្រគ្នាទៅវិញទៅមកផ្នែកធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការផ្គត់ផ្គង់បរិក្ខា ពេទ្យ (២)មិនត្រូវអនុវត្តវិធានការឯកតោភាគី ដែលអាចរាំងស្ទះដល់សកម្មភាពពាណិជ្ជកម្មឆ្លងព្រំដែន និងសកម្មភាពសេដ្ឋកិច្ចនានា (៣)គាំទ្រ «វប្បធម៌ចែករំលែក» ដើម្បីជួយកាត់បន្ថយសម្ពាធការចំណាយ របស់រដ្ឋាភិបាល (៤)ជៀសវាងការរើសអើងជាតិសាសន៍ ការចោទប្រកាន់ និងការស្តីបន្ទោស (៥)ជួយ ប្រជាជនអាស៊ាន ដែលបានជាប់គាំងដោយសារវិបត្តិនេះ និង(៦)ពិចារណាតើត្រូវស្តារសេដ្ឋកិច្ចដោយវិធី ណា នៅពេលការរាតត្បាតនៃជំងឺនេះត្រូវបានបញ្ចប់ ។

ថ្នាក់ដឹកនាំអាស៊ាន ក៏បានអនុម័តនូវសេចក្តីថ្លែងការណ៍របស់កិច្ចប្រជុំកំពូលអាស៊ានពិសេស ស្តីពី ជំងឺរាតត្បាតកូវីដ-១៩។

**កិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេស ស្តីពីជំងឺកូវីដ-១៩ (COVID-19)**

ថ្នាក់ដឹកនៃបណ្តាប្រទេសអាស៊ានបូកបី បានឯកភាពគ្នាឲ្យមានការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន បូកបីពិសេស នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ដើម្បីពិភាក្សាអំពីកិច្ចប្រឹងប្រែង និងវិធានការឆ្លើយតប តំបន់ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩។ **ឯកឧត្តម បណ្ឌិត តេដរ៉ូស អាដហាណុម ហ្គេប្រេយេស៊ូស** (Tedros Adhanom Ghebreyesus) អគ្គនាយកនៃអង្គការសុខភាពពិភពលោក ដែល

បានចូលរួមកិច្ចប្រជុំកំពូលនេះ បានកោតសរសើរដល់កិច្ចប្រឹងប្រែងរបស់ប្រទេសអាស៊ានបូកបីក្នុងការទប់ស្កាត់ ការពារ គ្រប់គ្រង និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការរីករាលដាលនៃជំងឺនេះ និងបានកត់សម្គាល់ថា តំបន់អាស៊ីបូព៌ាជាកន្លែងដំបូងដែលទទួលរងផលប៉ះពាល់អវិជ្ជមានពីជំងឺរាតត្បាតនេះ។

ថ្នាក់ដឹកនាំអាស៊ានបានទទួលស្គាល់ចំពោះកិច្ចប្រឹងប្រែងរបស់ប្រទេសបូកបី រួមមាន ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ ដែលបានខិតខំទប់ស្កាត់ការរីករាលដាលនៃជម្ងឺដ៏កាចសាហាវនេះ ដោយបានធ្វើឲ្យចំនួនអ្នកឆ្លងថ្មីមានការធ្លាក់ចុះនាពេលថ្មីៗនេះ។ ដូចនេះ ថ្នាក់ដឹកនាំអាស៊ាននឹងត្រៀមចូលរួមពិភាក្សា និងធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងឧត្តមានុវត្តន៍ ជាមួយប្រទេសបូកបី ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានបណ្តាលមកពីជំងឺនេះ ដើម្បីធានានូវសុខុមាលភាពប្រជាជនក្នុងតំបន់អាស៊ីបូព៌ា និងតំបន់ដទៃក្នុងពិភពលោក។ ក្នុងន័យនេះ កិច្ចប្រជុំបានទទួលស្គាល់ពីសារៈសំខាន់នៃការបម្រុងទុកអង្ករគ្រាមានអាសន្នរបស់ប្រទេសអាស៊ានបូកបី (ASEAN Plus Three Emergency Rice Reserve) ដែលជាយន្តការពង្រឹងសន្តិសុខស្បៀងក្នុងអាស៊ានបូកបី។

កិច្ចប្រជុំបានពិភាក្សាលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យផ្សេងៗ តាមរយៈយន្តការក្នុងតំបន់ដែលមានស្រាប់ ជាពិសេស ដើម្បីគាំទ្រសហគ្រាសមីក្រូ ធុនតូច និងមធ្យម (MSMEs) ការពារគ្រូពេទ្យជំនាញនិងបុគ្គលិកសុខាភិបាល ក៏ដូចជា ធានាសុវត្ថិភាពដល់ពលករចំណាកស្រុក។ កិច្ចប្រជុំក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការបន្តរក្សាសង្វាក់ផ្គត់ផ្គង់សម្ភារៈវេជ្ជសាស្ត្រ និងបន្តធ្វើពាណិជ្ជកម្មរវាងប្រទេសអាស៊ានបូកបី ដើម្បីធានានូវលំហូរនាំចេញ-ចូលទំនិញ និងសម្ភារៈចាំបាច់នៅតាមព្រំដែន។ កិច្ចប្រជុំក៏បានគូសបញ្ជាក់ផងដែរ អំពីសារៈសំខាន់នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ(RCEP) ក្នុងឆ្នាំនេះ ទោះបីមានវិបត្តិសុខភាពក៏ដោយ ព្រោះវាអាចជួយស្តារសេដ្ឋកិច្ចតំបន់ឲ្យរស់រវើកឡើងវិញបន្ទាប់ពីជំងឺកូវីដ-១៩ ចប់។

**សម្តេចតេជោនាយករដ្ឋមន្ត្រីតេជោ ហ៊ុន សែន** បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរងផលប៉ះពាល់អវិជ្ជមានដោយសារជំងឺរាតត្បាតនេះ និងបានសង្កត់ធ្ងន់ពីភាពចាំបាច់នៃការពង្រឹងសាមគ្គីភាពតំបន់ក្នុងការប្រយុទ្ធប្រឆាំងជម្ងឺនេះ។ ក្នុងបរិបទនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានកោតសរសើរដល់ប្រទេសបូកបីដែលបានជួយឧបត្ថម្ភគាំទ្រដល់កម្ពុជា ទាំងផ្នែកហិរញ្ញវត្ថុ សម្ភារៈបរិក្ខាពេទ្យ ក៏ដូចជាការបញ្ជូនវេជ្ជបណ្ឌិតមកជួយកម្ពុជា។

ក្នុងឱកាសនេះដែរ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ក៏បានលើកនូវចំណុចអាទិភាពមួយចំនួនសម្រាប់អាស៊ានបូកបីពិចារណា ដែលជាវិធានការជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំង គ្រប់គ្រង និងកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩៖ (១) ការចែករំលែកឧត្តមានុវត្តន៍ និងបទពិសោធន៍ក្នុងការទប់ស្កាត់ការរីករាលដាលនៃជម្ងឺនេះប្រកបដោយប្រសិទ្ធភាព (២) ការការពារសុខភាពសាធារណៈតាមរយៈការពង្រឹងសមត្ថភាពផលិតសម្ភារៈបរិក្ខាពេទ្យ និងការការពារអ្នកងាយទទួលរងគ្រោះ (៣) កាត់បន្ថយហានិភ័យសេដ្ឋកិច្ចបណ្តាលមកពីជំងឺរាតត្បាតនេះ (៤) ពង្រឹងសមាហរណកម្មតំបន់ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញ និង (៥) ពង្រឹងការតភ្ជាប់ផ្នែកឌីជីថលនៅក្នុងវិស័យផ្សេងៗ ដូចជា

រដ្ឋាភិបាលឌីជីថល(e-government) ធុរកិច្ចឌីជីថល(e-business) និងការសិក្សាតាមប្រព័ន្ធឌីជីថល (e-education)។

ថ្នាក់ដឹកនាំអាស៊ានបូកបី ក៏បានអនុម័តនូវសេចក្តីប្រកាសរួមរបស់កិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេសស្តីពីកូវីដ-១៩៕

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០